**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ស៊ីគ្លូ (ខេមបូឌា )ឯ.ក**

អាសយដ្ឋានៈ លេខផ្ទះ លេខផ្លូវ 44 ភូមិ បូរីកម្មករ ឃុំ/សង្កាត់ ច្បារមន ក្រុង/ស្រុក/ខណ្ឌ ច្បារមន រាជធានី/ខេត្ត កំពង់ស្ពឺ

**កិច្ចព្រមព្រៀង**

**រវាង**

**ក្រុមហ៊ុន ស៊ីគ្លូ ( ខេមបូឌា )ឯ.ក និង**

**តំណាងកម្មករ-កម្មការិនី (ប្រតិភូបុគ្គលិក) ប្រចាំក្រុមហ៊ុន**

នៅថ្ងៃទីប្រាំបី ខែកញ្ញា ឆ្នាំ២០២០នៅ **ក្រុមហ៊ុន ស៊ីគ្លូ( ខេមបូឌា )ឯ.ក** មានបើកកិច្ចប្រជុំមួយជាមួយថ្នាក់ដឹកនាំរោងចក្រ នឹងតំណាងកម្មករ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីបានយល់ព្រមព្រៀងគ្នាដូចខាងក្រោមៈ

១- ភាគីទាំងពីរយល់ព្រមព្យួរកិច្ចសន្យាការងាររយៈពេល០៧ថ្ងៃ ចំពោះកម្មករនិយោជិតមួយចំនួន ២១២៣នាក់ មានផ្នែក ដេរ ផ្នែកវិចខ្ចប់ បង្ហើយការ ផ្នែកតុកាត់ ផ្នែកពិនិត្យគុណភាព ផ្នែកឃ្លាំង នឹង ផ្នែកផ្សេងៗ ។ ដោយគិតចាប់ពីថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០ដោយសារតែខ្វះវត្ថុធាតុដើមព្រោះប្រទេសដែលផលិតវត្ថុធាតុដើមកំពុងរងផលប៉ះពាល់ពីជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ កូវីដ១៩(COVID19)។

២- ភាគីកម្មករនិយោជិតយល់ព្រមទទួលប្រាក់ឧបត្ថម្ភ ១០ដុល្លារអាមេរិក ពីភាគីនិយោជក និង ១៥ដុលារអាមេរិក ដែលជាប្រាក់ឧបត្ថម្ភពិសេសរបស់រាជរដ្ឋាភិបាលដូច្នេះសរុបកម្មករនិយោជិតម្នាក់ទទួលបាន ២៥ដុល្លារអាមេរិកក្នុងរយៈពេលព្យួរការងារ ០៧ថ្ងៃ នេះ។

៣- ក្រុមហ៊ុននិងបើកជូនប្រាក់ឧបត្ថម្ភ១០ ដុលារអាមេរិកនេះជូនកម្មករនិយោជិតបន្ទាប់ពីចូលធ្វើការវិញធម្មតា។

៤- បងប្អូនត្រូវត្រលប់ចូលធ្វើការវិញនាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០២០ ក្នុងករណីបងប្អូនកម្មករមិនបានចូលធ្វើការតាមកាលកំណត់នេះទេ ក្រុមហ៊ុននិងអនុវត្តន៏តាមច្បាប់ស្តីពីការងារនិងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះចាប់អនុវត្តន៏និងមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

កំពង់ស្ពឺ ថ្ងៃ ៦រោច ខែ ភទ្របទ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

ត្រូវនិងថ្ងៃ អង្គារ ទី ០៨ ខែ កញ្ញា ឆ្នាំ ២០២០

**តំណាង ប្រតិភូបុគ្គលិក**

1,ផុន ទិត្យសុខហឿន

2,ខេង ពៅ

3,ផៃ ចាន់នឿន

4,យុន ណារ៉ែន

5,ឈួន ស្រីមុំ

6,សិទ្ធ សារ៉ាន់

**នាយកក្រុមហ៊ុន**

ក្រុមហ៊ុន ស៊ីគ្លូ (ខេមបូឌា) ឯ.ក

រដ្ឋបាល

H.R.D

SIGLO (CAMBODIA) CO.,LTD